# ចំណេះចំណានខាងគោលលទ្ធិ ៖ ការវាយតម្លៃទី ២—សៀវភៅមគ្គុទេសក៍ការសិក្សា

សៀវភៅសិក្សាព្រះគម្ពីរសញ្ញាថ្មី សម្រាប់ថ្នាក់សិក្ខាសាលា

## ទន្ទេញចាំសេចក្ដីយោង និងឃ្លាបទគម្ពីរគន្លឹះ

សូមស្គាល់វគ្គបទគម្ពីរចំណេះចំណានខាងគោលលទ្ធិ និងឃ្លាបទគម្ពីរគន្លឹះ ។ អ្នកប្រហែលជាចង់ទាញយក និងប្រើកម្មវិធីឧបករណ៍ចល័តចំណេះ ចំណានខាងគោលលទ្ធិ ដើម្បីជួយអ្នកឲ្យរំឭកឡើងវិញ ។

| | |
|---|---|
| កូរិនថូស ទី១ ៦:១៩–២០ | « រូបកាយអ្នករាល់គ្នាជាវិហារនៃព្រះវិញ្ញាណបរិសុទ្ធ » ។ |
| កូរិនថូស ទី១ ១១:១១ | « ក្នុងព្រះអម្ចាស់ នោះបុរសមិនមែនជាឥតពឹងអាស្រ័យដល់ស្ត្រីឡើយ ហើយស្ត្រីក៏មិនមែនជាឥតពឹងអាស្រ័យដល់បុរសដែរ » ។ |
| កូរិនថូស ទី១ ១៥:២០–២២ | « ព្រោះដូចជាគ្រប់មនុស្សទាំងអស់បានត្រូវស្លាប់ក្នុងលោកអ័ដាមជាយ៉ាងណា នោះគ្រប់គ្នាក៏នឹងបានប្រោសឲ្យរស់ក្នុងព្រះគ្រីស្ទយ៉ាងនោះដែរ » ។ |
| កូរិនថូស ទី១ ១៥:៤០–៤២ | នៅក្នុងដំណើររស់ឡើងវិញ មានលំដាប់នៃសិរីល្អចំនួនបី ។ |
| អេភេសូរ ១:១០ | « សម្រាប់ការកាន់កាប់ត្រួតត្រា ក្នុងកាលដែលពេលពេញកំណត់បានមកដល់ ដើម្បីនឹងបំព្រួមគ្រប់ទាំងអស់ក្នុងព្រះគ្រីស្ទ » ។ |
| អេភេសូរ ២:១៩–២០ | សាសនាចក្រត្រូវបាន « ស្អាងឡើងលើជើងជញ្ជាំងនៃពួកសាវក និងពួកហោរា ហើយព្រះយេស៊ូវគ្រីស្ទនោះឯង ទ្រង់ជាថ្មជ្រុងយ៉ាងឯក » ។ |
| ថែស្សាឡូនីច ទី២ ២:១–៣ | « ថ្ងៃនៃព្រះអម្ចាស់ … មិនមកឡើយ ទាល់តែមានសេចក្ដីក្បត់សាសនាមកជាមុន » ។ |
| ធីម៉ូថេ ទី២ ៣:១៥–១៧ | « បទគម្ពីរទាំងប៉ុន្មាន… អាចនឹងនាំឲ្យអ្នកមានប្រាជ្ញាដល់ទីសង្គ្រោះ » ។ |
| ហេព្រើរ ១២:៩ | ព្រះវរបិតាសួគ៌គឺជា « ព្រះវរបិតាខាងវិញ្ញាណ » ។ |
| យ៉ាកុប ១:៥–៦ | « តែបើអ្នករាល់គ្នាណាមួយខ្វះប្រាជ្ញា មានតែសូមដល់ព្រះ » ។ |
| យ៉ាកុប ២:១៧–១៨ | « សេចក្ដីជំនឿ បើគ្មានការប្រព្រឹត្តតាមទេ នោះក៏ស្លាប់ » ។ |
| ពេត្រុស ទី១ ៤:៦ | « ដំណឹងល្អ [ ត្រូវបាន ] ផ្សាយទៅមនុស្សដែលស្លាប់ហើយ » ។ |
| វិវរណៈ ២០:១២ | « ហើយមនុស្សស្លាប់ទាំងអស់ត្រូវជំនុំជម្រះ … តាមអំពើដែលគេបានប្រព្រឹត្តរៀងខ្លួន » ។ |

## អនុវត្តគោលលទ្ធិទៅនឹងស្ថានភាពជីវិតជាក់ស្ដែង

- សូមប្រើវគ្គបទគម្ពីរចំណេះចំណានខាងគោលលទ្ធិមួយ ឬច្រើន ដើម្បីជួយនរណាម្នាក់ដែលចង់បានការណែនាំ សម្រាប់ធ្វើការសម្រេចចិត្តសំខាន់ៗនៅក្នុងជីវិតរបស់ពួកគេ ។
- ប្រសិនបើអ្នកត្រូវបង្រៀននរណាម្នាក់អំពីអ្វីដែលកើតឡើងនៅក្នុងផែនការរបស់ព្រះ ចំពោះព្រលឹងព្រះបុត្រីរបស់ទ្រង់បន្ទាប់ពីសេចក្ដីស្លាប់ តើវគ្គបទគម្ពីរចំណេះចំណានខាងគោលលទ្ធិនៃព្រះគម្ពីរសញ្ញាថ្មីមួយណាដែលអ្នកអាចប្រើ ? តើអ្នកអាចប្រើវគ្គបទគម្ពីរទាំងនេះដើម្បីបង្ហាញអំពីសេចក្ដីស្រឡាញ់របស់ព្រះចំពោះយើងដោយរបៀបណា ?

សូមត្រៀមខ្លួនដើម្បីចែកចាយវគ្គបទគម្ពីរចំណេះចំណានខាងគោលលទ្ធិណាដែលជះឥទ្ធិពលដល់អ្នកខ្លាំងបំផុត ។ តើវគ្គបទគម្ពីរនោះបង្រៀនអ្នកអ្វីខ្លះអំពីព្រះវរបិតាសួគ៌និងព្រះយេស៊ូវគ្រីស្ទ ?

## គោលការណ៍នៃការទទួលបានចំណេះដឹងខាងវិញ្ញាណ

សូមរំឭកកថាខណ្ឌទី ៥–១២ នៅក្នុងផ្នែក « ការទទួលបានចំណេះដឹងខាងវិញ្ញាណ » នៃ *ឯកសារគោលនៃចំណេះចំណានខាងគោលលទ្ធិ* ( ឆ្នាំ ២០២២ ) ។

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© ២០២២ by Intellectual Reserve, Inc. All rights reserved. កំណែ ៖ ២/២១ ។ ការបកប្រែនៃ *New Testament Doctrinal Mastery: Assessment 2—Study Guide* ។
Cambodian ។ PD60012661 258. Printed in the United States of America.